ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

របាយការណ៍
កិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែធ្នូ ឆ្នាំ២០២១
ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង ម៉ូលី**

នៅព្រឹកថ្ងៃអង្គារ ៩កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែធ្នូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង ម៉ូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ កិច្ចប្រជុំនេះមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកនាងកញ្ញា ជាអនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ទីប្រឹក្សា ជំនួយការ ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធានការិយាល័យ សរុបចំនួន៤៧នាក់។

គោលបំណងនៃកិច្ចប្រជុំ:

- ដើម្បីរាយការណ៍ពីបច្ចុប្បន្នភាពនៃសកម្មភាពរបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ដើម្បីបានដឹងពីស្ថានភាពរាលដាល និងគោលដៅនៃការឆ្លើយតបនឹងមេរោគអេដស៍ និងបទអន្តរាគមន៍។
- ដើម្បីបានដឹងពីសមិទ្ធផលដែលសម្រេចបាន និងឧបសគ្គដែលកើតមានឡើងក្នុងការអនុវត្តផែនការសកម្មភាព និងលើកផែនការសកម្មភាពអនុវត្តសម្រាប់ខែបន្ទាប់។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី មានប្រសាសន៍ស្វាគមន៍ ដល់មន្ត្រីរាជការទាំងអស់ដែលបានចូលរួម និងបានជម្រាបជូនពីដំណើរការនៃកិច្ចប្រជុំតាមរបៀបវារៈដូចខាងក្រោម ៖

១) បទបង្ហាញស្តីពីផែនការសកម្មភាព និងថវិកាអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំឆ្នាំ២០២២ ដោយឯកឧត្តម **ឈឹម ឃិនជារ៉ែត**។
២) បទបង្ហាញ ស្តីពីការសម្របសម្រួលការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០២២-២០២៣ ដោយឯកឧត្តមវេជ្ជបណ្ឌិត **ង៉ា ផល** អនុប្រធានទទួលបន្ទុកបច្ចេកទេស។
៣) មតិសំណេះសំណាលរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី
៤) កិច្ចការផ្សេងៗ។

បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតជូន ឯកឧត្តម អគ្គលេខាធិការ ធ្វើបទបង្ហាញ

ដោយមានការអនុញ្ញាតពី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម **ឈឹម ឃិនដារ៉ែត** អគ្គលេខាធិការ បានធ្វើបទបង្ហាញស្តីពី ៖

I- **ផែនការសកម្មភាព និងថវិកាអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំឆ្នាំ ២០២២**

១- វឌ្ឍនភាពនៃកម្មវិធីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

- បានផ្លាស់ប្តូរពីប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមជ្ឈការ ទៅជាប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម និងវិមជ្ឈការ
- ការផ្សារភ្ជាប់រវាងអាទិភាពជាតិ និងគោលនយោបាយតាមវិស័យ
- ទំនាក់ទំនងរវាងរចនាសម្ព័ន្ធគ្រប់គ្រង រចនាសម្ព័ន្ធគោលនយោបាយ និងសិទ្ធិអំណាច
- រៀបចំពិនិត្យ កែសម្រួល ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល។

២- យន្តការនៃការរៀបចំថវិកាកម្មវិធីរបស់ក្រសួងសុខាភិបាល

- លើកកម្ពស់លទ្ធផលសុខភាពប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង និងបង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុក្នុងការប្រើប្រាស់សេវាថែទាំសុខភាព។
- ប្រមូលទិន្នន័យ និងព័ត៌មាន ដើម្បីធ្វើការវិភាគ បកស្រាយ ប្រើប្រាស់ទៅតាមគោលដៅនៃការពិនិត្យតាមដានប្រចាំត្រីមាស និងប្រចាំឆ្នាំ។

៣- ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥

- ចក្ខុវិស័យ ប្រទេសកម្ពុជាគ្មានជំងឺអេដស៍ សុខភាពប្រសើរសម្រាប់ប្រជាជនទាំងអស់។
- អនុវត្តយុទ្ធសាស្ត្រ ការពារ ព្យាបាល ថែទាំ គាំទ្រ សមាហរណកម្ម ឋាមវន្ត គាំពារសង្គម បរិយាកាសគាំទ្រ ហិរញ្ញវត្ថុក្នុងស្រុក និងសង្គមស៊ីវិល។

៤- គម្រោងផែនការសកម្មភាព និងថវិកាអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២២

- រៀបចំគម្រោងផែនការសកម្មភាពដែលបានកំណត់លើក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្ត យន្តការស្ថាប័ន យន្តការគាំទ្រហិរញ្ញវត្ថុ
- ការឆ្លើយតបនឹងតម្រូវការសកម្មភាពអាទិភាព ធនធាន ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងចីរភាព
- បុរេសកម្ម សកម្ម អន្តរសកម្ម និងម៉ឺងម៉ាត់ជាងមុន។
- ប្រយ័ត្នប្រយែង សន្សឹមៗ ឈរលើគោលការណ៍ប្រាកដនិយម ទន់ភ្លន់ និងរៀនផង-ធ្វើផង។

៥- បញ្ហាប្រឈម ៖

- ភាពមិនប្រាកដប្រជានៃការរាតត្បាតមេរោគកូវីដ-១៩ (Omicron, Deltacron,...)
- អភិក្រមការងារមិនទាន់មានភាពត្រឹមបន្សុំ និងប្រទាក់ក្រឡាគ្នាបានល្អនៅឡើយ (ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងដៃគូ)។

- នីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មួយចំនួនមានកែសម្រួលថ្មី។

II- **បទបង្ហាញ ស្តីពីការសម្របសម្រួលការឆ្លើយតបនឹងមេរោគអេដស៍ និងដំណឹអេដស៍ឆ្នាំ២០២២-២០២៣ ដោយ ឯកឧត្តម ទា ផល**

- រៀបចំអនុវត្តសេចក្តីជូនដំណឹងលេខ២១៣ សជណ.សស (SCN213) ដោយដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (NSPV) នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ទទួលស្គាល់ការចូលរួមរបស់សហគមន៍ (ប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍) និងសកម្មភាពរួម ដើម្បីដោះស្រាយរបាំងផ្លូវច្បាប់ដោយចាប់ជាមួយដៃគូនានាគ្រប់កម្រិតនៃរចនាសម្ព័ន្ធឆ្លើយតបនឹងអេដស៍របស់ជាតិ។
- បញ្ចប់វិសមភាព បញ្ចប់អេដស៍ បញ្ចប់ជំងឺឆ្លងរាតត្បាតសកល ដោយយកប្រជាពលរដ្ឋជាធំ ក្នុងន័យប្រឹងប្រែងស្តាប់ពីតម្រូវការពលរដ្ឋ ហើយរៀបចំសេវាស្របតាមតម្រូវការពលរដ្ឋ ពិសេសពលរដ្ឋងាយរងគ្រោះ។
- *អភិក្រម* ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ដោយឈរលើសរសេរស្តម្ភទាំង៣ គឺទី១)- ***ពង្រឹងភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់ការ*** (Leadership and ownership) ទី២)- ***ភាពជាដៃគូ*** (Partnership) ទី៣)- ***ការវិនិយោគ*** (Investment)មានសារៈសំខាន់ក្នុងការជំរុញការឆ្លើយតបនឹងជំងឺអេដស៍ ដូច្នេះត្រូវពង្រឹងអនុវត្តនៅគ្រប់កម្រិត។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាអ្នកអនុវត្តនូវគោលនយោបាយរបស់ជាតិ ជាអ្នកដឹកនាំ សម្របសម្រួលការងារ ពិនិត្យតាមដាន និងវាយតម្លៃ ក្រសួង ស្ថាប័ន រាជធានី/ខេត្ត ក្រុង និងអង្គការក្រៅរដ្ឋាភិបាល។
- រយៈពេលពីរឆ្នាំខាងមុខ មានការងារច្រើនក្នុងផែនការយុទ្ធសាស្ត្រជាតិដែលត្រូវជម្រុញដើម្បីសម្រេចបាននូវគោលដៅ បញ្ចប់ការរាលដាលមេរោគអេដស៍នាឆ្នាំ២០២៥។

III- **មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី**

បន្ទាប់មក កិច្ចប្រជុំបានដំណើរការបន្តនៅក្នុងរបៀបវារៈទី៣ ក្នុងនោះឯកឧត្តមទេសរដ្ឋមន្ត្រី បានមានប្រសាសន៍សំណេះសំណាល និងផ្តល់នូវអនុសាសន៍លើចំណុចសំខាន់ៗដូចខាងក្រោម ៖

១- សកម្មភាពអាទិភាពឆ្នាំ ២០២២ គួរពិនិត្យអំពីទំនាក់ទំនងគ្នារវាង NSP V និង ស.ជ.ណ.សស ២១៣ ដែលត្រូវអនុវត្តព្រមគ្នា ពិសេសរាជធានី និងខេត្ត គម្រោងពន្លឿនទីក្រុងក្នុងការឆ្លើយតបនឹងមេរោគអេដស៍ Fast Tract Cities។

២- សកម្មភាពអាទិភាព គឺទី១) ដំណើរការ គណកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ ជាមួយនឹងសកម្មភាពការងារ និងថវិកា ២) ការរុករកអ្នកមិនមកទទួលសេវាព្យាបាល (១២,000 ករណី)។ ៣) ការគ្រប់គ្រងសភាពការណ៍ MSM ៤) វិធានការបង្ការការឆ្លងថ្មី (កុំឲ្យលើសពី ១នាក់ក្នុងមួយថ្ងៃ)។

៣- ត្រូវរុករកអ្នកមិនមកទទួលសេវា ដែលមានចំនួន១២,000 ករណី និងបង្ការការពារកុំឱ្យរីករាលដាលជំងឺអេដស៍ ដោយសហការជាមួយ NCHADS និងស្ថាប័នពាក់ព័ន្ធទាំងអស់។

៤- ត្រូវពិនិត្យអំពីកម្មវិធីមូលនិធិសកលទាំងមូល ដែលយើងទទួលខុសត្រូវអនុវត្ត និងត្រូវសម្របសម្រួលអនុវត្ត។

៥- យើងត្រូវរួមគ្នាធ្វើឲ្យចេញជាផែនការប្រតិបត្តិសកម្មភាព តាមកាលបរិច្ឆេទ និងតាមមុខសញ្ញា ដោយមានសូចនាករច្បាស់លាស់ ដើម្បីធ្វើអោយសម្រេចនូវផែនការយុទ្ធសាស្ត្រជាតិទី៥។

៦- ឯការប្រជុំត្រូវរៀបចំតាមលំដាប់លំដោយគ្នា ដើម្បីឲ្យស៊ីសង្វាក់គ្នា ដូចជា ការប្រជុំថ្នាក់ដឹកនាំ NAA ត្រូវប្រជុំយ៉ាងតិច ៣ថ្ងៃក្រោយ Technical Board ដើម្បីឱ្យអគ្គលេខាធិការមានឱកាសរៀបចំរបាយការណ៍ជូនអង្គប្រជុំថ្នាក់ដឹកនាំ NAA ឯ TAB ត្រូវប្រមូលរបាយការណ៍វឌ្ឍនភាពពីក្រុមការងារតាមយុទ្ធសាស្ត្រ។

៧- Steering Committee ដែលពង្រីកបន្ថែមពីក្រុម GDJ TWG គួរប្រជុំក្រោយ Technical Board រាល់បីខែម្តង និង បើអាចធ្វើបាន ក្រោយប្រជុំ CCC រាល់បីខែម្តង ដើម្បីឱ្យមានធាតុចូលគ្រប់គ្រាន់ក្នុងការពិភាក្សា និងផ្តល់យោបល់លើរបាយការណ៍វឌ្ឍនភាពធ្វើដោយ TAB។

៨- ក្នុងកិច្ចប្រជុំ Policy Board ម្តងៗ TAB ត្រូវប្រមូល Inputs ពីក្រុមការងារយុទ្ធសាស្ត្រទាំងអស់ និងធាតុចូលរបស់ GDJ ដាក់ក្នុងរបាយការណ៍របស់អគ្គលេខាធិការដើម្បីរាយការណ៍។ អគ្គលេខាធិការត្រូវចេះសង្ខេបរបាយការណ៍ឱ្យខ្លី ខ្លឹម និង ទាន់ពេលវេលា។

៩- អគ្គលេខាធិការ ត្រូវសហការ ជាមួយគណៈកម្មាធិការអេដស៍ក្រសួងមហាផ្ទៃ ដើម្បីពិនិត្យវឌ្ឍនភាពការងារ និងឱ្យគាត់ណែនាំដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី/ខេត្ត ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

១០- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ជាស្ថាប័នមួយតូច ប៉ុន្តែការងារទទួលខុសត្រូវធំទូលាយ និងពហុវិស័យ សូមជំរុញធ្វើការងារជាមួយក្រសួង ស្ថាប័ននានា ដែលមានការទទួលខុសត្រូវទូទាំងប្រទេស មានការកិច្ចត្រួតពិនិត្យ សម្របសម្រួល និងណែនាំអនុវត្តប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីឈានទៅរកភាពជោគជ័យ ។

១១- ត្រូវរួមគ្នា ***ពង្រឹងប្រព័ន្ធជាតិ*** (strengthening country system) ប្រមូលស្តិតិឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អ.ជ.ប.ជ.អ ពិសេសតួលេខមុនផ្សព្វផ្សាយត្រូវការពិនិត្យពី អ.ជ.ប.ជ.អ។

១២- ភាពជោគជ័យមួយទៀត គឺការរៀបចំកិច្ចប្រជុំពេញអង្គ និងសន្និបាត អ.ជ.ប.ជ.អ ដែលមានការចូលរួមគ្រប់ក្រសួងស្ថាប័ន និងបានផ្តល់របាយការណ៍គ្រប់ៗគ្នា ព្រមទាំងអនុវត្តសកម្មភាពតាមការណែនាំរបស់ អ.ជ.ប.ជ.អ។

១៣- ត្រូវឱ្យមានការចូលរួមមតិរបស់អង្គការសង្គមស៊ីវិល ហើយជម្រុញឱ្យគាត់មកប្រជុំក្នុងនាមជាអ្នកតំណាងរបស់សហគមន៍ ពិតប្រាកដ។

១៤- ក្នុងកិច្ចប្រជុំប្រចាំខែនៅឆ្នាំ២០២២ ត្រូវផ្តល់ធាតុចូលឱ្យបានច្រើន ឯកឧត្តមទេសរដ្ឋមន្ត្រីផ្តល់លទ្ធភាពជូនឯកឧត្តម លោកជំទាវ (អនុប្រធាន អគ្គលេខាធិការរង) ណាដែលចង់ធ្វើបទបង្ហាញ ឬបញ្ចេញមតិលើសកម្មភាពអ្វីមួយ សូម ផ្តល់ប្រធានបទទៅអគ្គលេខាធិការ ឬទៅនាយកខុទ្ទកាល័យជាមុន ដើម្បីដាក់ចូលក្នុងរបៀបវារៈ។

១៥- រាល់កិច្ចប្រជុំ ឯកឧត្តម **ហោ ប៊ុនឆ្មេង** ជាអ្នករៀបចំរបាយការណ៍ជាភាសាអង់គ្លេស។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការអនុវត្តការងារឱ្យបានកាន់តែប្រសើរឡើង។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១:១៧នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃអង្គារ ៩កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០២២

បានឃើញ និងឯកភាព
ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

អៀន_មូលី

អ្នកធ្វើរបាយការណ៍

ស៊ឹត_ថនឆាន់